ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តឧត្តរមានជ័យ
សំណុំរឿងរដ្ឋប្បវេណីលេខ ០៩៨
ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩
សាលក្រមលេខ៖ ១១២(ខ)
ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តឧត្តរមានជ័យ

-បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៧១៩/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ ។

-បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ និងបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ ដោយមានសមាសភាព៖

ចៅក្រមជំនុំជម្រះ

លោក **កុល កំឡូល** ជាអនុប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ

ក្រឡាបញ្ជី

លោក **កុយ ដុល្លា** ជាក្រឡាបញ្ជីសាលាដំបូងខេត្តឧត្តរមានជ័យ

-ដើមចោទឈ្មោះ តជ ភេទប្រុស អាយុ៣៥ឆ្នាំ
មានអាសយដ្ឋាននៅ
រាជធានីភ្នំពេញ ។

-ចុងចម្លើយឈ្មោះ ច១ ភេទស្រី អាយុ៤៦ឆ្នាំ សញ្ជាតិខ្មែរ និងប្តីឈ្មោះ ច១-២ អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន
ខេត្តឧត្តរមានជ័យ ត្រូវជាអ្នកខ្ចី ។

-ចុងចម្លើយឈ្មោះ ច២ ភេទស្រី អាយុ៣០ឆ្នាំ សញ្ជាតិខ្មែរ និងប្តីឈ្មោះ ច២-២ អាយុ៣១ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ខេត្តឧត្តរមានជ័យ ត្រូវជាអ្នកធានា ។

អង្គហេតុ និងការអះអាងរបស់គាត់

ក.ខ្លឹមសារនៃសាលក្រមដែលចាមចារដោយដើមចោទ ៖

១-ប្តឹងទាមទារប្រាក់ដើមពីចុងចម្លើយចំនួន ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេនដុល្លារអាមេរិក) ពីចុងចម្លើយ ។

២-ប្តឹងទាមទារការប្រាក់ចំនួន ១,៧ % ក្នុងមួយខែគិតចាប់ពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងរួច ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីដាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

៣-ប្រាក់ពិន័យ ៣% ក្នុងមួយខែ លើប្រាក់ដើមចំនួន ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេនដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ (ករណីហួសកាលកំណត់សងចុងក្រោយនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩) រហូតដល់ថ្ងៃសងប្រាក់រួច ។

៤-ករណីគ្មានប្រាក់សងបង្គាប់ឲ្យឈ្មោះ ច២ ភេទស្រី អាយុ៣០ឆ្នាំ សញ្ជាតិខ្មែរ និងប្តីឈ្មោះ ច២-២ អាយុ៣១ឆ្នាំ ត្រូវជាអ្នកធានាសងប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យជំនួស ។

៥-ប្តឹងទាមទារប្រាក់ជំងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ៣០០០ ដុល្លារអាមេរិក ។

៦-សុំអនុវត្តសាលក្រមជាបណ្តោះអាសន្នត្រង់ចំណុចទី១ ។

ខ.អង្គហេតុ និងចំណុចវិវាទ

ខ.១.ការសន្មេបរឿងក្តី

កាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ បានរួមគ្នាមកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ ចំនួន ១០.០០០ $ (មួយម៉ឺនដុល្លារអាមេរិក) ដោយបានព្រមព្រៀងគ្នាអនុវត្តនូវអត្រាការប្រាក់ ១,៧ % (មួយក្បៀសប្រាំពីរភាគរយ) ក្នុងមួយខែ ព្រមទាំងការប្រាក់ពិន័យ ៣% ក្នុងមួយខែ អនុវត្តករណីហួសកាលកំណត់សងចុងក្រោយថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ដោយខ្ចីរយៈពេល ៤៨ ខែ របៀបសង ការប្រាក់និងប្រាក់ដើមរាល់០៤ខែម្តង ដោយបង់តាមតារាងកាលវិភាគសងប្រាក់ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ដោយមានអ្នកធានាកាតព្វកិច្ចឈ្មោះ ច២ និងប្តីឈ្មោះ ច២-២ ។

តែចុងចម្លើយបានខកខានអនុវត្តសងប្រាក់តាមតារាងកាលវិភាគសងប្រាក់ និងបានបំពានយ៉ាងធ្ងន់ធ្ងរនូវកាតព្វកិច្ចដែលមានចែងក្នុងកិច្ចសន្យាខ្ចីបរិភោគ ។

ខ.២.អង្គហេតុដែលគ្មានវិវាទ

-ចុងចម្លើយបានទទួលស្គាល់ថាខ្លួនពិតជាបានចុះកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ជាមួយដើមចោទប្រាកដមែន ។

-ចុងចម្លើយបានទទួលស្គាល់ថាខ្លួនពិតជាបានចុះកិច្ចសន្យាដាក់ធានាចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ។

-ចុងចម្លើយបានទទួលស្គាល់ថា ខ្លួនពិតជាខកខានសងប្រាក់គិតចាប់ពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៧ រហូតដល់មកដល់បច្ចុប្បន្ននេះ ទៅឲ្យដើមចោទពិតប្រាកដមែន ។

-ដើមចោទអះអាងថាចុងចម្លើយនៅជំពាក់ប្រាក់ដើមចំនួន ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេនដុល្លារអាមេរិក) ហើយចុងចម្លើយឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ ក៏ទទួលស្គាល់ពិតជានៅជំពាក់ប្រាក់ដើមចំនួន ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេនដុល្លារអាមេរិក) ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

-ចុងចម្លើយឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ បានទទួលស្គាល់ថាពិតជាបានជំពាក់ការប្រាក់ ១,៧% ក្នុងមួយខែ លើប្រាក់ដើមនៅសល់ចំនួន ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេនដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី០៧ ខែ វិច្ឆិកា ឆ្នាំ២០១៧ ពីដើមចោទប្រាកដមែន ។

-ដើមចោទទាមទារប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យ ពីអ្នកធានាឈ្មោះ ច២ និងប្តីឈ្មោះ ច២-២ ករណីឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ គ្មានប្រាក់សង ហើយអ្នកធានាក៏សុខចិត្តជួយសងបំណុលរបស់ឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ ដែរ ។

-ចុងចម្លើយឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ បានទទួលស្គាល់ថាពិតជាបានជំពាក់ ប្រាក់ពិន័យ ៣% ក្នុងមួយខែ លើដើមនៅសល់ចំនួន ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេនដុល្លារអាមេរិក) ករណីអនុវត្តហួសកាលកំណត់សងថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ពីដើមចោទប្រាកដមែន ។

ខ.៣.ចំណុចវិវាទ

-ដើមចោទប្តឹងទាមទារជំងឺចិត្ត ៣០០០ ដុល្លារអាមេរិក ពីចុងចម្លើយ ដោយផ្អែកលើកិច្ចសន្យាចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ តែចុងចម្លើយអះអាងបដិសេធតបថាខ្លួនគ្មានប្រាក់សងនោះទេ ដោយសារប្រាក់នេះមានចំនួនពេក ហើយនៅពេលផ្តិតមេដៃ គឺខ្លួនពុំបានគិតឲ្យបានដិតដល់ ។

-ដើមចោទប្តឹងទាមទារតុលាការចេញសាលក្រមអនុវត្តបណ្តោះអាសន្នលើប្រាក់ដើម ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេនដុល្លារអាមេរិក) តែចុងចម្លើយឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ បានបដិសេធទាំងស្រុងលើការទាមទារនេះ ព្រោះខ្លួនមានលទ្ធភាពសងទៅដើមចោទ និងស្នើសុំតុលាការទុកពេលវេលាឲ្យខ្លួនរកប្រាក់សងទៅដើមចោទ ។

ខ.៤.ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ

ខ.៤.១.ចំណុចវិវាទទី១

ដើមចោទឈ្មោះ តដ ភេទប្រុស អាយុ៣៤ឆ្នាំ

នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនប្តឹងទាមទារប្រាក់ជំងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ៣០០០ ដុល្លារអាមេរិក ពីចុងចម្លើយ ដោយសារមូលហេតុថាខាងគ្រឹះស្ថានត្រូវចំណាយពេលវេលាឡើងចុះមកតុលាការ ការស្នាក់នៅ និងចំណាយផ្សេងៗទៀត ដូចមានក្នុងប្រការ ១០ នៃកិច្ចសន្យាចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ។

ចុងចម្លើយឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ បានធ្វើសេចក្តីថ្លែងការណ៍តបថា ខ្លួនមិនទទួលស្គាល់ការទាមទារប្រាក់ជំងឺចិត្តចំនួន ៣០០០ ដុល្លារអាមេរិក ព្រោះការទាមទារនេះ

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីដាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

ច្រើនលើសលប់ពេក ហើយខ្លួនគ្មានលទ្ធភាពសងផង តែខ្លួនទទួលស្គាល់ថាពិតជាបានចុះកិច្ចសន្យាចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ។

ខ.៤.២.ចំណុចវិវាទទី២

ដើមចោទឈ្មោះ តដ ភេទប្រុស អាយុ៣៤ឆ្នាំ

នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ បានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនប្តឹងសុំអនុវត្តសាលក្រមជាបណ្តោះអាសន្នត្រង់ប្រាក់ដើមចំនួន ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេនដុល្លារអាមេរិក) ពីចុងចម្លើយឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ ដោយមូលហេតុថា ឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ ពុំបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ហើយម៉្យាងចុងចម្លើយបានព្រមព្រៀងត្រង់ប្រការ ៤ នៃកិច្ចសន្យាដាក់ធានាចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ។

ចុងចម្លើយឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ បានធ្វើសេចក្តីថ្លែងការណ៍តបថា ខ្លួនសូមបដិសេធការទាមទារអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើម ព្រោះខ្លួនមានលទ្ធភាពសងប្រាក់ទៅឲ្យដើមចោទ ។

សំអាងហេតុ

ក.ស្តីពីចំណុចវិវាទទី១

ក.១.អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់

ចុងចម្លើយឈ្មោះ ច១ ភេទស្រី អាយុ៤៦ឆ្នាំ និងប្តីឈ្មោះ ច១-២ អាយុ៤៩ឆ្នាំ បានទទួលស្គាល់ថាកាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ខ្លួនបានមកខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ ចំនួន ១០.០០០ $ (មួយម៉ឺនដុល្លារអាមេរិក) និងបានចុះកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ដោយមានអ្នកធានាឈ្មោះ ច២ និងប្តីឈ្មោះ ច២-២ ហើយខ្លួនបានសងបំណុលជាបន្តបន្ទាប់ ។ រហូតមកដល់បច្ចុប្បន្ននេះ ខ្លួននៅជំពាក់បំណុលចំនួន ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេនដុល្លារអាមេរិក) ដូចការសេចក្តីថ្លែងការណ៍របស់ដើមចោទប្រាកដមែន ។

ក.២.ការវិនិច្ឆ័យអំពីចំណុចវិវាទ

ចុងចម្លើយឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ បានទទួលស្គាល់អង្គហេតុដែលជាមូលហេតុនៃការទាមទារដែលមានកិច្ចសន្យាខ្ចីប្រាក់ និងការទាមទារប្រាក់ដើមនៅជំពាក់ចំនួន ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេនដុល្លារអាមេរិក) របស់ដើមចោទនៅចំពោះមុខតុលាការ គប្បីតុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទតាមមាត្រា **១២៣ កថាខណ្ឌទី២** នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

ខ.ស្តីពីចំណុចវិវាទទី២

ខ.១.អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់

ចុងចម្លើយឈ្មោះ ច១ ភេទស្រី អាយុ៤៦ឆ្នាំ និងប្តីឈ្មោះ ច១-២ អាយុ៤៩ឆ្នាំ បានទទួលស្គាល់ថាខ្លួនពិតជាបានខកខានសងការប្រាក់ ១,៧ % (មួយក្បៀសប្រាំពីរភាគរយ) ក្នុងមួយខែ គិតចាប់ពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងរួច ដូចការលើកឡើងរបស់ដើមចោទប្រាកដមែន និងមានកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ដាក់ជូនតុលាការ ។

ខ.២.ការវិនិច្ឆ័យអំពីចំណុចវិវាទ

ការប្តឹងទារទាមរបស់ដើមចោទលើការប្រាក់ចំនួន ១,៧ % (មួយក្បៀសប្រាំពីរភាគរយ) ក្នុងមួយខែ គិតចាប់ពីថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងរួច និងមានការទទួលស្គាល់ពីចុងចម្លើយផងនោះមានលក្ខណៈសមស្របតាមមាត្រា **៥៨៤ កថាខណ្ឌទី២** នៃក្រមរដ្ឋប្បវេណី, **មាត្រា ៤ និងមាត្រា ៥** នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិកម្ពុជាចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ និងប្រកាសស្តីពីការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់លេខ ធ៧-០៩-២១៣ ប្រ.ក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ ព្រោះថាត្រង់ចំណុចនេះមានបញ្ជាក់ក្នុងកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ដោយចុងចម្លើយឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ បានព្រមព្រៀងទទួលយកតាមលក្ខខណ្ឌនេះរួចហើយ ហេតុដូច្នេះគប្បីតុលាការទទួលស្គាល់ការទាមទារការប្រាក់នេះ ។

គ.ស្តីពីចំណុចវិវាទទី៣

គ.១.អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់

ចុងចម្លើយឈ្មោះ ច១ ភេទស្រី អាយុ៤៦ឆ្នាំ និងប្តីឈ្មោះ ច១-២ អាយុ៤៩ឆ្នាំ បានទទួលស្គាល់ថាខ្លួនពិតជាបានព្រមព្រៀងលក្ខខណ្ឌប្រាក់ពិន័យ ៣% ក្នុងមួយខែ លើប្រាក់ដើមនៅជំពាក់ គិតចាប់ពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ (ករណីហួសកាលកំណត់សងចុងក្រោយនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩) រហូតដល់ថ្ងៃសងរួច ដូចការលើកឡើងរបស់ដើមចោទប្រាកដមែន ។

គ.២.ការវិនិច្ឆ័យអំពីចំណុចវិវាទ

ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាទទួលយកលក្ខខណ្ឌនេះរួចហើយ ដូចមានកិច្ចសន្យាចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ ជាសំអាងភស្តុតាងស្រាប់ គប្បីតុលាការពិចារណាតាមឆន្ទៈរបស់ដើមចោទ និងចុងចម្លើយដែលបានព្រមព្រៀងគ្នាផ្អែកតាមកិច្ចសន្យា និងសេចក្តីថ្លែងការណ៍ទទួលស្គាល់របស់ចុងចម្លើយនៅចំពោះមុខតុលាការ ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

ឃ.ស្តីពីចំណុចវិវាទទី៤

ឃ.១.អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់

-ដើមចោទឈ្មោះ ដ ទាមទារប្រាក់ដើម ការប្រាក់ និងប្រាក់ពិន័យ ពីអ្នកធានាឈ្មោះ ច២ និងប្តីឈ្មោះ ច២-២ ករណីឈ្មោះ ច១ និងប្តីឈ្មោ ច១-២ គ្មានប្រាក់សង ហើយអ្នកធានាឈ្មោះ ច២ និងប្តីឈ្មោះ ច២-២ ក៏សុខចិត្តជួយសងបំណុលរបស់ឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ ដែរ ហេតុដូច្នេះចំណុចនេះគឺអង្គហេតុគ្មានវិវាទដែលអង្គហេតុ និងការទាមទារនេះត្រូវបានអ្នកធានាទទួលស្គាល់ផងដែរ ។

ឃ.២.ការវិនិច្ឆ័យអំពីចំណុចវិវាទ

ចុងចម្លើយឈ្មោះ ច២ និងប្តីឈ្មោះ ច២-២ ជាអ្នកធានាបានទទួលយកលក្ខខណ្ឌដែលមាននៅក្នុងកិច្ចសន្យាធានាចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ និងសេចក្តីថ្លែងការណ៍ទទួលស្គាល់របស់អ្នកធានាឈ្មោះ ច២ ក្នុងការអនុវត្តកាតព្វកិច្ចសងជំនួសឲ្យអ្នកខ្ចីឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ រីឯអ្នកធានាឈ្មោះ ច២-២ ពុំមានវត្តមាននៅនីតិតុលាការនោះទេ ខណៈដែលតុលាការបានធ្វើការកោះហៅត្រឹមត្រូវតាមច្បាប់ ហេតុដូច្នេះតុលាការចាត់ទុកថាឈ្មោះ ច២-២ ទទួលស្គាល់អង្គហេតុ និងការទាមទាររបស់ដើមចោទ ហេតុដូច្នេះគប្បីតុលាការពិចារណាការទាមទាររបស់ដើមចោទ។

ង.ស្តីពីចំណុចវិវាទ៥

ង.១.អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់

ចុងចម្លើយ និងដើមចោទបានទទួលស្គាល់ថានៅក្នុងដំណើរនីតិវិធីរឿងក្តីគូភាគីពិតជាត្រូវការចំណាយពេលវេលាឡើងចុះមកតុលាការ ខាតបង់ពេលវេលាទាំងសង្ខាងក្នុងការរកស៊ី និងខាតបង់ផលប្រយោជន៍នៅក្នុងដំណើរការរឿងក្តីប្រាកដមែន ។

ង.២.ការវិនិច្ឆ័យអំពីចំណុចវិវាទ

ការប្តឹងទាមទារជំងឺ និងខាតបង់ពេលវេលាចំនួន ៣.០០០ $ (បីពាន់ដុល្លារអាមេរិក) តែចុងចម្លើយបដិសេធលើការទាមទារនេះដោយសារខ្លួនគ្មានប្រាក់នោះទេ ។ ប៉ុន្តែការប្តឹងទាមទាររបស់ដើមចោទមានមូលហេតុសមស្រប អាចឲ្យតុលាការពិចារណាបានដោយហេតុថាការខកខានពុំបានបង់ប្រាក់ដើម និងការប្រាក់របស់ចុងចម្លើយឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ ពិតជាបានធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ និងប្រតិបត្តិការសាច់ប្រាក់របស់ដើមចោទយ៉ាងពិតប្រាកដមែន ប៉ុន្តែការទាមទារនេះលើសលប់ពេក តុលាការគប្បីពិចារណាលើបញ្ហានេះដោយផ្អែកលើព្យសនកម្មជាក់ស្តែង ។

ច.ស្តីពីចំណុចវិវាទ៦

ច.១.អង្គហេតុដែលគ្មានវិវាទ ហើយត្រូវបានទទួលស្គាល់

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

ចុងចម្លើយបានទទួលស្គាល់ថាខ្លួនពិតជាបានចុះកិច្ចសន្យាចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០១៥ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ ប្រាកដមែន ដោយភ្ជាប់ជាមួយ (ខ) សន្យាអនុញ្ញាត ឲ្យខាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ អាចអនុវត្តទាមទារទៅតុលាការលក់ដោយបង្ខំលើទ្រព្យដែលបានដាក់ធានា (កិច្ចសន្យាដាក់ធានាចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥) នៅពេលដែលខ្លួនគ្មានប្រាក់ទូទាត់បំណុល ប្រាកដមែន ។

ច.២.ការវិនិច្ឆ័យអំពីចំណុចវិវាទ

ចុងចម្លើយឈ្មោះ ច១ និងប្តីឈ្មោះ ច១-២ បានបដិសេធលើការប្តឹងទាមទារអនុវត្តសាលក្រមជាបណ្តោះអាសន្នរបស់ដើមចោទ ក៏ប៉ុន្តែតុលាការពិនិត្យឃើញថាចុងចម្លើយបានទទួលស្គាល់អង្គហេតុខ្ចីប្រាក់ និងការទាមទារលើប្រាក់ដើមចំនួន ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេនដុល្លារអាមេរិក) ហេតុដូច្នេះដើម្បីជៀសវាងការប៉ះពាល់ផលប្រយោជន៍របស់ដើមចោទកាន់តែធ្ងន់ធ្ងរនោះ គប្បីតុលាការពិចារណាលើការសម្រេចឲ្យមានការអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើម ជាបំណុលអាទិភាពដែលចុងចម្លើយទទួលស្គាល់ស្របតាមមាត្រា **១៩៦** នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ឆ.សេចក្តីសន្និដ្ឋាន

រាល់សេចក្តីថ្លែងការណ៍របស់ចុងចម្លើយដែលបានទទួលស្គាល់អង្គហេតុ និងការទាមទាររបស់ដើមចោទ (ប្រាក់ដើម, ការប្រាក់, ប្រាក់ពិន័យ និងកាតព្វកិច្ចអ្នកធានាត្រូវសងជំនួសម្ចាស់បំណុល) គឺតុលាការពិចារណាលើការទទួលស្គាល់នេះដែលជាអង្គហេតុគ្មានវិវាទដោយពុំចាំបាច់ផ្អែកលើកស្តុតាងឡើយដើម្បីធ្វើជាមូលដ្ឋានក្នុងសម្រេចសេចក្តីតាមមាត្រា **១២៣ កថាខណ្ឌទី២** នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ រីឯការបដិសេធរបស់ចុងចម្លើយលើការទាមទារសំណងជំងឺចិត្តរបស់ដើមចោទ និងការទាមទារអនុវត្តជាបណ្តោះអាសន្ននោះ ហាក់នៅមិនទាន់មានមូលដ្ឋានសមស្របនោះទេ ដោយហេតុហេតុការខកខានសងប្រាក់របស់ចុងចម្លើយបានបង្កឲ្យសនកម្មដល់ដើមចោទ ហើយចុងចម្លើយក៏ទទួលស្គាល់ថានៅជំពាក់ប្រាក់ដើមប្រាកដមែន គប្បីតុលាការពិចារណាសម្រេចសំណងជំងឺចិត្ត និងការអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើម ។

ជាសរុប តុលាការនឹងសម្រេចរឿងក្តីប្រាក់កម្ចីនេះ ដូចខាងក្រោម៖

សេចក្តីសម្រេចបញ្ចប់

១-បង្គាប់ឲ្យចុងចម្លើយឈ្មោះ ច១ ភេទស្រី អាយុ៤៦ឆ្នាំ សញ្ជាតិខ្មែរ និងប្តីឈ្មោះ ច១-២ អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ សងប្រាក់ដើមចំនួន ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេនដុល្លារអាមេរិក) មកឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ដែលតំណាងដោយឈ្មោះ តដ ភេទប្រុស អាយុ៣៤ឆ្នាំ

នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ ជាដើមចោទ ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីដាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

២-បង្គាប់ឲ្យចុងចម្លើយឈ្មោះ ច១ ភេទស្រី អាយុ៤៦ឆ្នាំ សញ្ជាតិខ្មែរ និងប្តីឈ្មោះ ច១-២ អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ សងការប្រាក់ចំនួន ១,៧ % ក្នុងមួយខែគិតចាប់ពីថ្ងៃទី០៧ ខែវិឆ្ឆិកា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងរួច មកឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ ដែលតំណាងដោយ ឈ្មោះ តដ ភេទប្រុស អាយុ៣៤ឆ្នាំ នៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ ដើមចោទ ។

៣-បង្គាប់ឲ្យចុងចម្លើយឈ្មោះ ច១ ភេទស្រី អាយុ៤៦ឆ្នាំ សញ្ជាតិខ្មែរ និងប្តីឈ្មោះ ច១-២ អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ ប្រាក់ពិន័យ ៣% ក្នុងមួយខែ លើប្រាក់ដើមចំនួន ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេនដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ (ករណីហួសកាលកំណត់សងចុងក្រោយនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០១៩) រហូតដល់ថ្ងៃសងប្រាក់រួច មកឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ ដែលតំណាងដោយ ឈ្មោះ តដ ភេទប្រុស អាយុ៣៤ឆ្នាំ នៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ ជាដើមចោទ ។

៤-បង្គាប់ឲ្យឈ្មោះ ច២ ភេទស្រី អាយុ៣០ឆ្នាំ សញ្ជាតិខ្មែរ និងប្តីឈ្មោះ ច២-២ អាយុ៣១ឆ្នាំ (អ្នកធានា) សងប្រាក់ដើម ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេនដុល្លារអាមេរិក), ការប្រាក់ចំនួន ១,៧ % ក្នុងមួយខែគិតចាប់ពីថ្ងៃទី ០៧ ខែវិឆ្ឆិកា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងរួច និងប្រាក់ពិន័យ ៣% ក្នុងមួយខែ លើប្រាក់ដើម ចំនួន ៤,៩៤៦.១៩ ដុល្លារអាមេរិក (បួនពាន់ប្រាំបួនរយសែសិបប្រាំមួយ និងដប់ប្រាំបួនសេន ដុល្លារអាមេរិក) គិតចាប់ពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ (ករណីហួសកាលកំណត់សងចុងក្រោយ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩) រហូតដល់ថ្ងៃសងប្រាក់រួច មកឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលតំណាងដោយឈ្មោះ តដ ភេទប្រុស អាយុ៣៤ឆ្នាំ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ ជាដើមចោទ ករណីចុងចម្លើយឈ្មោះ ច១ អាយុ៤៦ឆ្នាំ និងប្តីឈ្មោ ច១-២ អាយុ៤៩ឆ្នាំ គ្មានប្រាក់សងបំណុល ។

៥.បង្គាប់ឲ្យចុងចម្លើយឈ្មោះ ច១ ភេទស្រី អាយុ៤៦ឆ្នាំ និងប្តីឈ្មោះ ច១-២ អាយុ៤៩ឆ្នាំ សងសំណងជំងឺចិត្តជាប្រាក់ចំនួន ២.០០០.០០០ រៀល (ពីរលានរៀល) មកឲ្យ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ ដែលតំណាងដោយឈ្មោះ តដ ភេទប្រុស អាយុ៣៤ឆ្នាំ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ ជាដើម ចោទ ។

៦.ចំណុចទី ១ (មួយ) ខាងលើនៃសេចក្តីសម្រេចក្នុងសាលក្រមនេះមានអានុភាពអនុវត្តជាប-ណ្តោះអាសន្នតាមមាត្រា **១៩៦** នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៧-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

សាលក្រមនេះ បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខដើមចោទ ឈ្មោះ តជ និងកំប៉ាំងមុខចុងចម្លើយឈ្មោះ ច១ ,ឈ្មោះ ច១-២ ឈ្មោះ ច២ និង ឈ្មោះ ច២-២ ។ ទុកសិទ្ធិឲ្យភាគីប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ គិតចាប់ពីថ្ងៃបានទទួលលិខិតសាលក្រមនេះ។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែអាសាឍ ឆ្នាំកុរឯកស័ក ព.ស ២៥៦៣
ធ្វើនៅឧត្តរមានជ័យ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩
ចៅក្រមជំនុំជម្រះ

កំណត់សំគាល់៖ សាលក្រមនេះជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ